# ខ្ញុំស្រេកទឹក!



និពន្ធដោយលោក អូលីវីយេ ឝ្មីតហាស្លែរ
អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

# មាតិកា

**ចំណងជើង** **ទំព័រ**

សារជូនពរក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរនិងបុណ្យចម្លង....................................១
សូមលាងជើងឲ្យគ្នាទៅវិញទៅមក........................................................................៦
ខ្ញុំស្រេកទឹក...........................................................................................................១០
ព្រះយេស៊ូបំភ្លឺពិភពលោក.......................................................................................១៣
ពិធីតែងតាំងសម្តេចប៉ាប យ៉ូហានទី ២៣ និង សម្តេចយ៉ូហានប៉ាប ប៉ូលទី២ ជាសន្ត
បុគ្គល................................................................................................................ ១៩



# សារជូនពរ
# ជូនបងប្អូនទាំងអស់ក្នុងភូមិភាគភ្នំពេញ
# ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនិងបុណ្យចម្លង

## បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះយើងជួបជុំគ្នា ជាឱកាសមួយ ដើម្បីយើងអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះជាម្ចាស់ប្រទានពរ សម្រាប់ព្រះសហគមន៍របស់យើង សម្រាប់ប្រទេសកម្ពុជាយើងនិងសម្រាប់ក្រុមគ្រួសារយើងនីមួយៗដែរ។ ថ្ងៃនេះ ជាថ្ងៃទីមួយ នៃថ្ងៃចូលឆ្នាំយើងមកជួបជុំគ្នាក្នុងអំណរសប្បាយរីករាយយ៉ាងខ្លាំង នេះជាសញ្ញាសម្គាល់ នៃជំនឿរបស់យើងដែលយើងកំពុងធ្វើដំណើររួមជាមួយគ្នាក្នុងអង្គព្រះគ្រីស្ត។ ជំនឿរបស់យើងមិនមែន ជាអ្វីផ្សេង ក្រៅពីជីវិតប្រចាំថ្ងៃរបស់យើងនោះទេ។ ព្រះយេស៊ូ មិនសូមឲ្យយើងជាគ្រីស្តបរិស័ទមានជំនឿ លើព្រះជាម្ចាស់ តែនៅពេលយើងចូលព្រះវិហារទេ ប៉ុន្តែ! ព្រះអង្គសូមឲ្យយើងមានជំនឿក្នុងជីវិតប្រចាំថ្ងៃរបស់យើង ឲ្យការរស់នៅរបស់យើង ប្រែទៅជាថ្មីនៅក្នុងប្រពៃណីក្នុងវប្បធម៌ក្នុងភាសារបស់យើងដោយសារយើងបានទទួលពន្លឺថ្មីពីជំនឿ។ សម្រាប់ឆ្នាំថ្មីនេះ ខ្ញុំសូមព្រះជាម្ចាស់ជាព្រះបិតាប្រទានព្រះពរ បីយ៉ាង ដល់ព្រះសហគមន៍នៅប្រទេសកម្ពុជាយើងទាំងមូល គឺ៖

**ទីមួយ ខ្ញុំសូមព្រះជាម្ចាស់ប្រទានព្រះពរឲ្យយើងបង្កើតភាតរភាព**

ភាតរភាពមានន័យថា យើងទទួលស្គាល់គ្នាជាបងប្អូនបង្កើត ដោយសារយើងមានព្រះបិតាតែមួយ។ ព្រះបិតាស្រឡាញ់យើងទាំងអស់ស្មើៗគ្នា។ ព្រះជាម្ចាស់ ដែលជាព្រះបិតា បានបង្កើតសត្វលោកទាំងឡាយ ព្រះបិតាបានបង្កើតមនុស្សទាំងឡាយ ណែនាំឲ្យមនុស្សទាំងអស់នៅលើផែនដីទៅជាបងប្អូនបង្កើត។

ប៉ុន្មានអាទិត្យមុន ពេលណែនាំសំណាក់ធម៌ ខ្ញុំសួរដល់បងប្អូន ១០៦ នាក់ដែល ជា

បេក្ខជនជំហានទីពីរ ក្នុងភូមិភាគភ្នំពេញថាៈ"តើបងប្អូននឹងទទួលអ្វីខ្លះ នៅពេលទទួលពិធីជ្រមុជទឹកហើយ?" មានម្នាក់បានឆ្លើយថា ៖ " ខ្ញុំ នឹងទទួលគ្រួសារថ្មីក្នុងព្រះសហគមន៍ " ។ ពិតមែន នេះជាចំណុចមួយដ៏សំខាន់ណាស់ ដែលណែនាំឲ្យយើងទទួលស្គាល់ថា យើងជាបងប្អូនបង្កើតពិតមែន។ ប៉ុន្តែ! នេះមិនទាន់ល្មមទេ ប្រសិនបើយើងគិតតែនៅក្នុងព្រះសហគមន៍របស់យើង។ យើងត្រូវការមើលឃើញដល់បងប្អូនដែលនៅជុំវិញយើង ទោះបីគេមិនមែនជាគ្រីស្តបរិស័ទក៏ដោយ ក៏គេជាបងប្អូនរបស់យើងដែរ។ ពេលយើងមាន ភ្នែកដូចនេះ ពេលយើងមានចិត្តដូចនេះ ណែនាំឲ្យជីវិតរបស់យើងជាប្រចាំថ្ងៃទៅជាជីវិតថ្មី ដោយសារយើងបានស្រឡាញ់មនុស្សទាំងអស់ ទុកជាបងប្អូនបង្កើត របស់ខ្លួន។

អ្នកណាជាបងប្អូនរបស់ខ្ញុំ? យើងឆ្លើយភ្លាម ៖ " បងប្អូនរបស់ខ្ញុំ គឺមនុស្សទាំងអស់ដែលមិនមែន ខ្ញុំ " នេះមានន័យថា គឺមនុស្សទាំងអស់ នៅក្នុងប្រទេសកម្ពុជា ជាង ១៤ លាននាក់ មនុស្សទាំងអស់នៅលើផែនដីប្រមាណ ៦ ពាន់លាននាក់ ជាបងប្អូនរបស់ខ្ញុំ។ ទោះបីយើងមិនអាចទាក់ទងជាមួយមនុស្ស ទាំងអស់នៅលើ ផែនដីនេះបាន ប៉ុន្តែនៅកន្លែងដែលយើងរស់នៅ នោះសូមឲ្យយើងរាប់មនុស្សដែល នៅជុំវិញយើងទុកជាបងប្អូនគ្នា។ ម៉្យាងទៀត ពេលយើងមើលទូរទស្សន៍ ពេលយើងស្តាប់វិទ្យុពេលយើងមើលអ៊ិនទែណែត សូមឲ្យយើងចាប់អារម្មណ៍ ដល់អស់បងប្អូនដែលនៅឆ្ងាយ ពីយើងដែលកំពុងរងទុក្ខ លំបាកក្នុងសង្គ្រាម ក្នុងភាពក្រីក្រ និងក្នុងអ្វីៗទាំងអស់ ដែលណែនាំឲ្យជីវិតរបស់គេអស់សង្ឃឹម សូមឲ្យយើងបង្កើតចិត្តទូលំទូលាយថែមទៀត ដោយសូមឲ្យយើងឲ្យហេតុការណ៍ទាំងនោះ ចូលនៅក្នុងការអធិដ្ឋានរបស់យើង។

**ទីពីរ ខ្ញុំសូមព្រះជាម្ចាស់ប្រទានពរ ឲ្យយើងទៅជាមនុស្សដែលចេះយកចិត្តទុកដាក់**

តួនាទីរបស់យើងជាគ្រីស្តបរិស័ទ គឺជាសាវ័ករបស់ព្រះយេស៊ូ ជាមិត្តសម្លាញ់របស់ព្រះអង្គ ប៉ុន្តែយើងមិនមែនតែជាសាវ័ក ជាមិត្តសម្លាញ់តែប៉ុណ្ណឹង គឺយើងជាគ្រីស្តទូតដែរ មានន័យថា យើងជាទូតរបស់ព្រះគ្រីស្ត យើងជាអ្នកប្រាប់ដំណឹងអំពីព្រះយេស៊ូដល់អ្នកដទៃឲ្យគេស្គាល់ព្រះអង្គ។ ដូច្នេះសូមឲ្យយើងយកចិត្តទុកដាក់ ក្នុងតួនាទីរបស់យើងដែលជាសាវ័កនិងជាគ្រីស្តទូតរបស់ព្រះគ្រីស្ត។ តើយើងធ្វើដូចម្តេចដើម្បីឲ្យតួនាទីរបស់យើងទៅមុខដោយយកចិត្តទុកដាក់ឲ្យអស់ពីអស់ពីកម្លាំងកាយចិត្តដល់មនុស្សឯទៀត?។

ព្រះយេស៊ូទន្ទឹងរង់ចាំយើង ជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ឲ្យកសាងព្រះសហគមន៍ ខ្មែរយ៉ាងពិតប្រាកដ ឲ្យកសាងព្រះសហគមន៍ខ្មែរដែលមានវត្តមាននៅក្នុង គ្រប់វិស័យសង្គមបច្ចុប្បន្ន។ គ្រប់កន្លែងដែលយើងរស់នៅ ទាំងនៅភ្នំពេញនិងជនបទតាមកន្លែងដែលយើងធ្វើការក្នុងវិស័យអប់រំវិស័យសុខភាពវិស័យអភិវឌ្ឍន៍ជនបទ សូមឲ្យវត្តមានរបស់យើង ទៅជាវត្តមាននៃសាវ័កនិងគ្រីស្តទូតរបស់ព្រះយេស៊ូ ដោយសូមឲ្យយើងយកចិត្តទុកដាក់រស់នៅស្របតាមព្រះបន្ទូល កុំឲ្យព្រះបន្ទូលចូលនៅក្នុងត្រចៀករបស់យើង តែពេលយើងនៅក្នុងព្រះវិហារតែប៉ុណ្ណោះ ប៉ុន្តែសូមឲ្យព្រះបន្ទូលចូលយ៉ាងជ្រៅនៅក្នុងដួងចិត្ត ក្នុងគំនិតឲ្យទៅជាផ្លូវតែមួយក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

យើងជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ យើងជាគ្រីស្តទូតពិតមែននោះ នាំឲ្យយើងនឹកដល់បងប្អូន ដែលពិបាកចិត្ត ឲ្យយើងមានចិត្តអាណិតមេត្តា នាំឲ្យយើងនឹកដល់បងប្អូនដែលឈ្លោះគ្នា ឲ្យយើងរកមធ្យោ-បាយ ឲ្យគេមានសន្តិភាពឡើងវិញ នាំឲ្យយើងនឹកដល់មនុស្សដែលវង្វេងផ្លូវ ឲ្យយើងទៅជាបងប្អូនបង្កើតដែល បំភ្លឺផ្លូវគេ នាំឲ្យយើងនឹកដល់មនុស្សដែលអស់សង្ឃឹមនៅក្នុងជីវិត ឲ្យយើងធ្វើជាមនុស្សដែលផ្តល់សេចក្តីសង្ឃឹមឲ្យគេវិញ។ យើងអាចធ្វើកិច្ចការទាំងនេះបាន ប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់យាងចូលនៅក្នុងខ្លួនរបស់យើង។ សូមកុំឲ្យយើងទុកទស្សនៈ នៃលោកីយ៍ដឹកនាំជីវិតរបស់យើង។

## ទីបី ខ្ញុំសូមព្រះជាម្ចាស់ប្រទានពរ ឲ្យយើងមានចិត្តបម្រើ

ប្រសិនបើគ្មានចិត្តជាអ្នកបម្រើ អ្វីៗដែលយើងធ្វើ វាមិនរីកចម្រើនសោះ ព្រោះយើងធ្វើដោយសារយើង ចង់បានរង្វាន់តាមលោកីយ៍ ដោយសារសង្ឃឹម ថាគេនឹងជួយយើងវិញ។ យើងដឹងហើយថា យើងជាគ្រីស្តបរិស័ទ បានទទួលរង្វាន់យ៉ាងពិសេសរួចហើយពីព្រះជាម្ចាស់ គឺជីវិតអស់កល្បជានិច្ច។ ដូច្នេះយើងត្រូវតែមានចិត្តបម្រើ ដែលណែនាំឲ្យយើងលះបង់។ ព្រះសហគមន៍ណែនាំឲ្យយើង លះបង់ប្រយោជន៍ផ្ទាល់ខ្លួន តាមគំរូព្រះយេស៊ូ ដែលបានលះបង់ចោលអ្វីៗទាំងអស់។ ព្រះយេស៊ូបានលាងជើងជូនក្រុមសាវ័កជាគំរូឲ្យយើងលាងជើងគ្នាទៅវិញទៅមក។ យើងត្រូវតែប្រព្រឹត្តិជាក់ស្តែងបម្រើគ្នាទៅវិញទៅមក នៅក្នុងព្រះសហគមន៍ និងក្នុងសង្គមដែរ។

ប្រសិនបើយើងទទួលព្រះពរទាំងបី គឺបង្កើតភាតរភាពឲ្យយើងទៅ ជាបងប្អូនបង្កើត

យ៉ាងពិតប្រាកដ ដោយយើងយកចិត្តទុកដាក់អស់ពីសេចក្តីស្រឡាញ់ ដោយយើងបង្ហាញចិត្តបម្រើពិតមែន នោះយើងដឹងថា នៅឆ្នាំមមីនេះ យើងទៅជាសាវ័កនិងទៅជាគ្រីស្តទូតរបស់ព្រះយេស៊ូដ៏ល្អប្រសើរបំផុត ក្នុងការកសាងព្រះសហគមន៍កម្ពុជា ដោយភ្ជាប់ជាមួយអំណរសប្បាយនិងទុក្ខលំបាករបស់បងប្អូនខ្មែរយើង។ សូមបង្កើតព្រះសហគមន៍កម្ពុជា ដែលមាននៅក្នុងទឹកដីកម្ពុជាយ៉ាងជ្រៅ មិនមែនជាព្រះសហគមន៍មួយ ដែលឆ្ងាយពីជីវិតប្រចាំថ្ងៃរបស់បងប្អូនយើង តែជាព្រះសហគមន៍កម្ពុជា ដែលជាសញ្ញាសម្គាល់នៃព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង។សូមព្រះជាម្ចាស់ប្រទានពរដើម្បីឲ្យឆ្នាំថ្មីនេះទៅជាឆ្នាំដែលប្រកបដោយសេចក្តីសុខប្រកប ដោយសេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ពិតមែនព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង!

អាលេលូយ៉ា! អាលេលូយ៉ា!




**អូលីវីយេ ឆ្មីតអឺស្លែរ**

**អភិបាលភូមិភាគភ្នំពេញ**













# សូមលាងជើងឲ្យគ្នាទៅវិញទៅមក
# ពិធីបុណ្យលាងជើងថ្ងៃព្រហស្បតិ៍ពិសិដ្ឋ
# នៅមឹងទំពុន ថ្ងៃទី ១៧/០៤/២០១៤

## បងប្អូនជាទីស្រលាញ់

ថ្ងៃនេះព្រះយេស៊ូជប់លៀងជាលើកចុងក្រោយនៅលើផែនដីនេះ ជាមួយក្រុមគ្រីស្តទូតរបស់ព្រះអង្គ។ ថ្ងៃនេះយើងក៏រួមជាមួយព្រះយេស៊ូ ជាមួយក្រុមគ្រីស្តទូតយ៉ាងជិតស្និទ្ធដែរ។ ខ្ញុំសូមអញ្ជើញបងប្អូនបិទភ្នែក ដើម្បីយើងចូលយ៉ាងជ្រៅនៅក្នុងអាថ៌ កំបាំងដែលកំពុងកើតឡើងនៅយប់នេះ។ ចូរយើងនឹកឃើញព្រះយេស៊ូនិងក្រុមគ្រីស្តទូត ១២នាក់ដែលអង្គុយរួមតុជាមួយគ្នា។ ក្រុមគ្រីស្តទូតជាអ្នកដែលបានធ្វើដំណើរជាមួយព្រះយេស៊ូអស់បីឆ្នាំ។ បីឆ្នាំនោះគេបានស្តាប់ព្រះបន្ទូល គេបានធ្វើដំណើរជាមួយព្រះអង្គពីភូមិមួយទៅភូមិមួយ គេបានឃើញព្រះយេស៊ូធ្វើសញ្ញាសម្គាល់អស្ចារ្យជាច្រើន ដូចជាព្រះអង្គប្រោសអ្នកជំងឺឲ្យជាសះស្បើយ មនុស្សខ្វាក់ឲ្យមើលឃើញជនពិការឲ្យដើរបាន។ ក្រុមគ្រីស្តទូតក៏បានស្តាប់ព្រះយេស៊ូមានព្រះបន្ទូលលើកលែងទោសឲ្យអ្នកបាប គឺព្រះជាម្ចាស់អត់ទោសបាបឲ្យគេ ក្រុមគ្រីស្តទូតបានឃើញដោយផ្ទាល់អំពីការរស់នៅរបស់ព្រះយេស៊ូ និងពួកគេក៏បានប្រកាសមុនគេបង្អស់ថា៖ " ព្រះយេស៊ូជាព្រះគ្រីស្តពិតមែន! ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ពិតមែន! "។

នៅពេលកំពុងធ្វើបុណ្យចម្លង ក្រុមគ្រីស្តទូតបាននឹកឃើញដល់លោកម៉ូសេ បាននឹកឃើញដល់ប្រ ជារាស្ត្រអ៊ីស្រាអែល ដែលបានចេញពីកណ្តាប់ដៃនៃជនជាតិអេស៊ីប។ ប៉ុន្តែយប់បុណ្យចម្លងនោះ គឺជាយប់មួយយ៉ាងពិសេស ដោយសារព្រះយេស៊ូបានលើកនំប៉័ងឡើង ហើយមានព្រះបន្ទូលថា៖ " នេះជារូបកាយរបស់ខ្ញុំ!" និងក្រោយមក ព្រះអង្គលើកពែងស្រាទំពាំងបាយជូរឡើង និងមានព្រះបន្ទូលយ៉ាងចម្លែកម្តងទៀតថា៖ "នេះជាលោហិតរបស់ខ្ញុំ !"។

យប់នេះជាពេលវេលាមួយយ៉ាងពិសេសនៅក្នុងជីវិតយើងដែលបន្តិចទៀតយើងនឹងឡើងទទួលព្រះ កាយនិងព្រះលោហិតព្រះគ្រីស្ត។ ដោយសារព្រះយេស៊ូព្រះបន្ទូលថា៖ "នេះជារូបកាយរបស់ខ្ញុំ និងនេះជាលោហិតរបស់ខ្ញុំ..." នោះយើងទាំងអស់គ្នា ក៏នឹង

ទទួលជីវិតថ្មី និងទទួលកម្លាំងថ្មីមកពីព្រះអង្គដោយផ្ទាល់ដែរ ហើយព្រះអង្គក៏ទៅជាធ្លុងតែមួយជាមួយយើងម្នាក់ៗ។ ក្រុមគ្រីស្តទូតមិនយល់អំពីអ្វីៗ ដែលកំពុងកើតឡើងទេ ដូចយើងក៏ឆ្ងល់អំពីព្រះយេស៊ូដែរ ប៉ុន្តែព្រះយេស៊ូនៅតែបន្តធ្វើកិច្ចការ ដែលព្រះអង្គបានធ្វើអស់ រយៈពេល៣ឆ្នាំកន្លងមក គឺព្រះអង្គលើកលែងទោសឲ្យ មនុស្សបាប ព្យាបាលអ្នកជំងឺនានា ឲ្យជាសះស្បើយព្រះអង្គស្វាគមន៍មនុស្ស តូចតាចនិងអ្នកមានដែរ គឺព្រះអង្គនៅតែបំពេញកិច្ចការរបស់ព្រះអង្គ ដើម្បីឲ្យក្រុមគ្រីស្តទូតឃើញថែមទៀត។

នៅយប់នោះព្រះយេស៊ូលាងជើងជូនក្រុមគ្រីស្តទូត នៅយប់នេះ ព្រះយេស៊ូក៏យាងមកលាងជើងឲ្យយើងដែរ លាងជើងដើម្បីបង្ហាញថា ព្រះជាម្ចាស់ដែលបានចាប់ កំណើតជាមនុស្សព្រះជាម្ចាស់ ដែលបានលះបង់ចោលឋានៈជាព្រះជាម្ចាស់យាងមកដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី និងដើម្បីឲ្យយើងបម្រើគ្នា និងស្រឡាញ់គ្នាទៅវិញទៅមក។

ពីថ្ងៃប្រសូត្ររហូតដល់ពេលជប់លៀងសាវ័ក អ្វីៗទាំងអស់ដែលព្រះយេស៊ូបាន ប្រព្រឹត្ត និងគ្រប់ព្រះបន្ទូលដែលព្រះអង្គបានប្រៀនប្រដៅ គឺសុទ្ធតែសម្រាប់បងប្អូន និងសម្រាប់អ្នកឯទៀតៗ មិនមែនសម្រាប់ ខ្លួនព្រះអង្គផ្ទាល់ទេ។ ព្រះយេស៊ូបានលាង ជើងជូនក្រុមគ្រីស្តទូត និងលាងយើងដែរ នេះគឺជាជីវិតរបស់ អ្នកបម្រើ គឺបម្រើបងប្អូនឯទៀតៗ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួន។ ព្រះអង្គក៏សូមឲ្យយើងទៅជាអ្នកបម្រើគ្នា ទៅវិញទៅមកដូចព្រះអង្គដែរ។

ការអស្ចារ្យយប់នេះ ណែនាំឲ្យយើងជាគ្រីស្តបរិស័ទ រកឃើញអត្ថន័យដ៏ពេញលក្ខណៈជាអ្នកបម្រើជាមួយព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះយេស៊ូ សូមឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកមិនមែនគ្រាន់តែល្អស្តាប់ គឺព្រះបន្ទូលដែលណែនាំ ឲ្យយើងអនុវត្តតាម ដែលប្លែកពីរបៀបមនុស្សលោកីយ៍និងពីសង្គមបច្ចុប្បន្ន។ ព្រះយេស៊ូណែនាំឲ្យ យើងស្រឡាញ់គ្នា ដោយបម្រើគ្នាទៅវិញទៅមក។ យប់នេះកុំឲ្យយើងភ្លេចបន្តរួមដំណើរជាមួយ ព្រះយេស៊ូ ដែលលាងជើងសាវ័ករួចហើយ ព្រះអង្គបានយាងទៅសួនច្បារកេតសេម៉ានី ដើម្បីអធិដ្ឋាន។នៅទីនោះងងឹតប៉ុន្តែព្រះអង្គអធិដ្ឋានទូលអង្វរព្រះបិតាយ៉ាងជិតស្និទ្ធនិងយ៉ាងពិសេស។

យប់នេះតាមរយៈព្រះកាយនិងព្រះលោហិតរបស់ព្រះយេស៊ូ តាមរយៈការបម្រើគ្នា និង តាមរយៈការអធិដ្ឋាន ជាមួយព្រះយេស៊ូនៅសួនច្បារកេតសេម៉ានី យើងទាំងអស់គ្នា

អាចចូលនៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់តាមរបៀបថ្មី ទទួលព្រះកាយព្រះគ្រីស្ត ធ្វើជាធ្លុងតែមួយជាមួយព្រះយេស៊ូ ដើម្បីបម្រើបងប្អូនឯទៀតៗដើម្បីមានជីវិតដូចព្រះយេស៊ូ និងចូលក្នុងសួនច្បារកេតសេម៉ានីដើម្បីអធិដ្ឋាន ទូលអង្វរព្រះនាងម៉ារី និងធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ គ្រប់កាលៈទេសៈគ្រប់ពេលវេលានៅក្នុងជីវិតរបស់យើង។

យប់នេះយើងអរព្រះគុណព្រះជាម្ចាស់អស់ពីដួងចិត្ត ដែលព្រអង្គបានចាប់កំណើតជាមនុស្ស អរព្រះគុណព្រះអង្គ ដែលស្រឡាញ់យើង ដោយយាងមករំដោះយើងពីភាពងងឹតនិងពីបាប ដែលនាំឲ្យជីវិតរបស់ យើងពោរពេញដោយពន្លឺ ពោរពេញ ដោយសេចក្តីស្រឡាញ់ពោរពេញដោយសេចក្តីសង្ឃឹម។ យប់នេះ យើងធ្វើដំណើរ រួមជាមួយព្រះយេស៊ូ ដោយអធិដ្ឋាន ដោយទូលអង្វរព្រះអង្គ សូមឲ្យយើងមានជំនឿមាំមួន កុំឲ្យយើងដេកលក់ក្នុងភាពងងឹត ឲ្យយើងយកចិត្តទុដាក់ជាមួយអ្នកគ្មានអាហារ ជាមួយអ្នកដែលគ្មានសម្លៀកបំពាក់ ជាមួយអ្នកជំងឺដែលគ្មានប្រាក់ទៅមន្ទីរពេទ្យជាមួយអ្នកអស់សង្ឃឹម អ្នកគ្មានទីពឹង...។ សូមឲ្យជំនឿរបស់យើង ណែនាំយើងទៅជាអ្នកបម្រើ ដែលមានចិត្តស្មោះ អ្នកបម្រើដែលសុចរិត អ្នកបម្រើតាមរបៀបព្រះយេស៊ូជាអ្នកបម្រើ។

អាម៉ែន!









# ខ្ញុំស្រេកទឹក
# ពិធីដើរផ្លូវឈើឆ្កាងថ្ងៃសុក្រពិសិដ្ឋ លើភ្នំបូកគោ
# ថ្ងៃទី ១៨/០៤/២០១៤

## បងប្អូនជាទីស្រលាញ់

ថ្ងៃនេះ យើងមកជួបជុំគ្នាដើម្បីគោរពព្រះយេស៊ូដែលរងទុក្ខលំបាកនិង សោយទិវង្គត។ អំបាញ់មិញយើងបានស្ដាប់អត្ថបទគម្ពីរស្ដីអំពីព្រះយេស៊ូរងទុក្ខលំបាក ជាពិសេសនៅពេលចុងក្រោយបង្អស់នៅលើឈើឆ្កាង ព្រះអង្គមានព្រះបន្ទូលថា៖ "ខ្ញុំស្រេកទឹក"។ "ខ្ញុំស្រេកទឹក" ជាព្រះបន្ទូល ដែលទទួលយកទុក្ខលំបាកគ្រប់បែបយ៉ាងទាំងអស់របស់មនុស្សយើង។ ពេលនេះ យើងនឹកឃើញដល់ប្រទេសកម្ពុជា និងនឹកឃើញដល់ប្រជាជនយើងទាំងអស់ដែរ ជាពិសេសយើងដឹងថា ព្រះបន្ទូលនេះ គឺសម្រាប់បងប្អូនដែលគ្មានដីភូមិធ្វើផ្ទះ សម្រាប់បងប្អូនដែលត្រូវគេបណ្ដេញចេញពីដីភូមិរបស់ខ្លួន សម្រាប់ប្រជាជនយើងដែលគ្មានសិទ្ធិ សម្រាប់មនុស្សតូចតាចដែលគ្មាននរណាគោរពសិទ្ធិរបស់គេ សម្រាប់អ្នកដែលគ្មាននរណាស្ដាប់សម្លេងរបស់គេ ប៉ុន្តែមានតែព្រះយេស៊ូទេដែលកំពុងស្ដាប់សម្លេងរបស់បងប្អូនទាំងនោះ មានតែព្រះយេស៊ូទេ ដែលកំពុងរងទុក្ខលំបាកជាមួយបងប្អូន ហើយព្រះអង្គមានព្រះបន្ទូលថា៖ "ខ្ញុំស្រេកទឹក"។

ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំស្រេកទឹក" ណែនាំឲ្យយើងនឹកឃើញ ដល់កម្មករកម្មការិនី ដែលពីមួយថ្ងៃទៅមួយថ្ងៃខិតខំធ្វើការ តែហូបមិនគ្រប់គ្រាន់ ខិតខំទាមទារសិទ្ធិរបស់ខ្លួន តែគ្មានអ្នកធំណា យកចិត្តទុកដាក់សោះ។ យើងក៏នឹកឃើញដល់ជនភៀសខ្លួនដែលគ្មានឯកសារ ហើយត្រូវបាត់បង់សិទ្ធិទាំងអស់ មិនអាចទៅសាលា គ្មានសិទ្ធិទទួលសេវាសុខភាព គ្មានសេចក្ដីសុខសាន្តនិងអំណរសប្បាយ។ ឲ្យយើងនឹកឃើញដល់បងប្អូនទាំងអស់ ដែលគ្មានសមត្ថភាព បញ្ជូនកូនទៅសាលា ដែលគ្មានសមត្ថភាពទៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺ។ ឲ្យយើងនឹកឃើញដល់បងប្អូនទាំងអស់ ដែលគ្មានការងារធ្វើ ពីមួយថ្ងៃទៅមួយថ្ងៃរស់នៅតាមដងផ្លូវសុំទានគេដើម្បីរកលុយ ចិញ្ចឹមកូន។

"ខ្ញុំស្រេកទឹក!" ណែនាំឲ្យយើងនឹកឃើញលល់កុមារកំព្រាគ្មានទីពឹង ដល់ចាស់ជរាដែលកូន ចៅមិនចាប់អារម្មណ៍ ដល់ស្ត្រីមេម៉ាយដែលគ្មាន អ្នកណាជួយគាំទ្រ ដល់អ្នកគ្មានខ្សែស្រឡាយគ្មានអ្នកធំណាជួយជំរុញឲ្យទៅមុខ ប៉ុន្តែយើងដឹងថា យើងមានខ្សែ

យ៉ាងពិសេសគឺព្រះយេស៊ូ ដោយសារព្រះយេស៊ូមានព្រះបន្ទូលថា "ខ្ញុំស្រេកទឹក!" គឺព្រះអង្គស្រេកធ្វើជាទីពឹង ធ្វើជាសេចក្តីសង្ឃឹមរបស់គេ។ ព្រះយេស៊ូស្រេកទឹក ណែនាំឲ្យយើងនឹកដល់មនុស្សទាំងអស់ដែលគ្មានចិត្តអាណិតមេត្តា ដែលមិនយកចិត្តទុកដាក់ចំពោះអ្នកដទៃ ដល់មនុស្សដែលមិនចេះលើកទឹកចិត្តអ្នកដែលគ្មានទីពឹង ដល់មនុស្សដែលគ្មានសីលធម៌រស់នៅដោយចិត្តចង្អៀតចង្អល់ដល់អ្នកដែលមានចិត្តលោភលន់ចង់បានថែមទៀតនិងថែមទៀតដែរ។

ព្រះយេស៊ូស្រេកទឹកនៅលើឈើឆ្កាង ណែនាំឲ្យយើងនឹកឃើញដល់បងប្អូនដែលគ្មានព្រះជាម្ចាស់នៅក្នុងជីវិតរបស់គេ ដែលគ្មានព្រះពន្លឺដឹកនាំ ដែលគ្មានសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់ដើម្បី បើកចិត្ត គំនិតគេឲ្យទូលាយ ឲ្យទទួលស្គាល់ថាមនុស្សទាំងអស់ទាំងអ្នកមានទាំងអ្នកក្រ ទាំងអ្នកធំ ទាំងអ្នកតូចជាបងប្អូននឹងគ្នា។

ថ្ងៃនេះព្រះយេស៊ូ ដែលសោយទិវង្គតនៅលើឈើឆ្កាង យាងចូលនៅក្នុងជីវិតរបស់យើងក្នុងទុក្ខលំបាករបស់យើង ក្នុងភាពងងឹតរបស់យើងដើម្បីឲ្យយើងរកឃើញសេចក្តីសង្ឃឹមរកឃើញពន្លឺមួយនៅក្នុងជីវិត។ ព្រះយេស៊ូយាងចូលក្នុងទុក្ខលំបាក របស់យើងដើម្បីឲ្យអស់អ្នកដែលគ្មានចិត្តមេត្តាករុណា គ្មានសីលធម៌ គ្មានព្រះជាម្ចាស់គង់នៅជាមួយក៏រកឃើញពន្លឺរបស់ព្រះអង្គដែរ។

ថ្ងៃនេះ ព្រះយេស៊ូដែលស្រេកទឹក សូមឲ្យយើងជាព្រះសហគមន៍កាតូលិក នៅប្រទេសកម្ពុជា ចេះមើលឃើញព្រះអង្គដែលកំពង់ស្រេកទឹកដើម្បីបងប្អូនទាំងអស់នៅក្នុងសង្គមរបស់យើង ដើម្បីឲ្យព្រះបន្ទូលរបស់ ព្រះអង្គណែនាំព្រះសហគមន៍របស់យើង ដើម្បីឲ្យការសោយទិវង្គតរបស់ព្រះអង្គណែនាំយើងឲ្យធ្វើជាសាក្សី នៃជីវិតអស់កល្បជានិច្ច ដើម្បីឲ្យយើង ចេះមើលឃើញទុក្ខលំបាករបស់បងប្អូន ដើម្បីឲ្យយើងចេះរក ផ្លូវរំដោះបងប្អូនចេញពីទុក្ខលំបាកទាំងនោះ ដើម្បីឲ្យព្រះជន្មអស់កល្បជានិច្ចរបស់ព្រះយេស៊ូណែនាំឲ្យយើងពោរពេញដោយអំណរសប្បាយ ដើម្បីឲ្យយើងមានចិត្តមេត្តាករុណា ដ៏ពេញលក្ខណៈ ដើម្បីឲ្យយើងរស់នៅក្នុង សេចក្តីសង្ឃឹមក្នុងឋានៈជាសាវ័ករបស់ព្រះអង្គ។

ថ្ងៃនេះព្រះយេស៊ូណែនាំ ឲ្យយើងលីឈើឆ្កាងរបស់ ព្រះអង្គឲ្យយើងលីឈើឆ្កាង របស់បងប្អូនឯទៀតដែរ និងឲ្យយើងរួមគ្នាកសាងព្រះសហគមន៍របស់ព្រះអង្គ នៅលើទឹកដីកម្ពុជាយើង។ អាម៉ែន!



# ព្រះយេស៊ូបំភ្លឺពិភពលោក
# ពិធីបុណ្យចម្លងនៅផ្សារតូច
# ថ្ងៃទី ១៩/០៤/២០១៤

## បងប្អូនជាទីស្រលាញ់

យប់នេះ នៅពេលចាប់ផ្តើមថ្វាយអភិបូជា យើងបានដុតភ្លើងគុប និងក្រោយមកយើងបានប្រកាសយ៉ាង ឱឡារិកថា" ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ!"។ អំបាញ់មិញពេលស្តាប់ព្រះគម្ពីរដំណឹងល្អ យើងបានឃើញរបៀប ដែលព្រះយេស៊ូបង្ហាញព្រះអង្គ ឲ្យស្រ្តីៗឃើញពេលព្រះអង្គមានព្រះជន្មរស់ឡើងវិញ នោះព្រះអង្គមានព្រះបន្ទូលថា៖ "ជម្រាបសួរនាង"។ពេលដឹងថាជាព្រះយេស៊ូ ពួកនាងៗស្ទុះមកឱបព្រះបាទាព្រះអង្គ ហើយក្រាបថ្វាយបង្គំផង។ យប់នេះ យើងមកទទួលព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ យើងមកទទួលព្រះអង្គដែលយាងមកបង្កើតទំនាក់ទំនងថ្មីជាមួយយើង ទាំងមានព្រះបន្ទូលថា៖"ជម្រាបសួរ" ដូចព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកស្រ្តីៗដូច្នោះដែរ ។ នៅពេលនេះ ប្រសិនបើយើងស្គាល់ព្រះយេស៊ូដែលគង់នៅយ៉ាងជ្រៅក្នុងដួងចិត្តរបស់យើង នោះយើងនឹងថ្វាយបង្គំព្រះអង្គយ៉ាងពិតប្រាកដដូចស្រ្តីៗដែរ។ ចំពោះយើងជាគ្រីស្តបរិស័ទ យើងបានទទួលសេរីរុងរឿងរបស់ព្រះជាម្ចាស់ យើងបានទទួលសេចក្តីសង្ឃឹមដ៏អស្ចារ្យពីព្រះអង្គ គឺយើងទទួលជីវិតដែលឈ្នះសេចក្តីស្លាប់។ យប់នេះ ព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ ឡើងវិញយ៉ាងពិតប្រាកដមែន ព្រះអង្គមានព្រះជន្មគង់នៅក្នុងពិភពលោក និងគង់នៅក្នុងជីវិតរបស់យើងម្នាក់ៗដែរ។ ក្នុងគម្ពីរបញ្ជាក់ថា យើងជាគ្រីស្តបរិស័ទបានបំពាក់ព្រះជាម្ចាស់ បានបំពាក់សេចក្តីសង្ឃឹម លើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ គឺព្រះអង្គគង់នៅជាមួយយើង។ វត្តមានរបស់បងប្អូនទាំងអស់នៅយប់នេះនៅទីនេះ ជាសញ្ញាសម្គាល់ពិតមែនថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងគង់នៅជាមួយយើង។

ជាង២០០០ឆ្នាំកន្លងមក ពិភពលោករបស់យើងបានប្រែប្រួលយ៉ាងច្រើន ប្រវត្តិសាស្រ្តក៏ចេះតែទៅមុខរហូត សង្គមរីកចម្រើន យ៉ាងច្រើន សូម្បីតែនៅប្រទេស កម្ពុជាយើង កាលពីប៉ុន្មានខែកន្លងមកនេះ ក៏បានប្រែប្រួលយ៉ាងច្រើនដែរប៉ុន្តែចំពោះគ្រីស្តបរិស័ទ យើង

ជឿថា ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ព្រះអង្គប្រទានពន្លឺមួយថ្មីដែលបំភ្លឺ ប្រវត្តិសាស្ត្រមនុស្ស បំភ្លឺសង្គមទាំងឡាយ បំភ្លឺមនុស្សលោកទាំងអស់ បំភ្លឺជីវិតរបស់យើងម្នាក់ៗ និងប្រទេសកម្ពុជាយើងដែរ ហើយយើងជាគ្រីស្តបរិស័ទ ទៅជាសញ្ញាសម្គាល់មួយនៃពន្លឺរបស់ព្រះយេស៊ូដែលបំភ្លឺពិភពលោក។ វត្តមានរបស់យើង គឺបំភ្លឺនិងជួយឲ្យសង្គមរបស់យើង និងជីវិតរបស់យើងផ្ទាល់ រកឃើញអត្ថន័យថ្មី ដោយសារព្រះយេស៊ូជាជីវិតជាសេចក្ដីពិតនិងជាផ្លូវ។ ដូច្នេះ កុំឲ្យយើងភ្លេចព្រះ ពន្លឺរបស់ព្រះយេស៊ូ ដែលបំភ្លឺពិភពលោកយើង។ យប់នេះ យើងរួមគ្នាប្រកាសអំពីព្រះ យេស៊ូជាអំណរ សប្បាយដ៏ពិសេសបំផុត របស់ពិភពលោកយើងទាំង មូល។ យប់នេះ យើងទទួល បេសកកម្មថ្មីមួយ ទៅជាសញ្ញាសម្គាល់នៃអំណរសប្បាយនេះសម្រាប់មនុស្សលោក។ រាល់ថ្ងៃអាទិត្យយើងបានស្ដាប់ដំណឹងល្អរបស់ព្រះយេស៊ូ តែយប់នេះ យើងបានស្ដាប់ដំណឹងល្អដែលជាកំពូលនៃដំណឹងល្អ ដែលគ្មាន ដំណឹងល្អណាល្អជាងដំណឹងល្អនេះទេ គឺព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនិងព្រះយេស៊ូគង់នៅជាមួយយើងហេតុដូច្នេះហើយបានជាអំបាញ់មិញនេះយើងបានហែរព្រះបន្ទូលរបស់ព្រះជាម្ចាស់ យ៉ាងឱឡារិកបំផុតដោយមានច្រៀងអាលេលូយ៉ាអស់ពីដួងចិត្តផង។

កាលពីយប់បុណ្យព្រះយេស៊ូប្រសូត យើងបានស្ដាប់ព្រះបន្ទូលអំពីព្រះយេស៊ូចាប់កំណើតជាមនុស្ស តែយប់នេះ យើងបានស្ដាប់ព្រះបន្ទូលយ៉ាងពិសេសមួយទៀតគឺព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងព្រះយេស៊ូគង់នៅជាមួយយើង។ ហេតុនេះហើយសូមឲ្យយើងទុកដំណឹងល្អនេះយ៉ាងជ្រៅ ក្នុងដួងចិត្តរបស់យើង និងឲ្យព្រះបន្ទូលនេះទៅជាអំណរសប្បាយសម្រាប់យើងពេញមួយឆ្នាំខាងមុខ និងសូមឲ្យយើងចែកអំណរសប្បាយនេះជាមួយមនុស្សដែលគ្មាសេចក្ដីសង្ឃឹម និងដែលទន្ទឹងរង់ចាំពន្លឺ ដូចយើងដែរ។

យប់នេះ យើងទទួលព្រះយេស៊ូជាព្រះសង្គ្រោះ ដោយសារព្រះអង្គបានឈ្នះសេចក្ដីស្លាប់។ ព្រះយេស៊ូសង្គ្រោះយើងចេញពីសេចក្ដីស្លាប់ ចូលនៅក្នុងជីវិតថ្មីអស់កល្បជានិច្ច។ បន្តិចទៀតបងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹក នឹងចូលនៅក្នុងទឹកដើម្បីរួមស្លាប់ និងចេញពីទឹកដើម្បីរួមរស់ជាមួយព្រះយេស៊ូដែល មានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូដែលជាព្រះសង្គ្រោះ យាងមកដើម្បីព្យាបាលមនុស្សលោក ដើម្បីព្យាបាលគ្រប់ជំងឺរបស់យើង ពិសេសជំងឺផ្លូវចិត្តដែលណែនាំឲ្យយើងរស់នៅក្នុងភាពងងឹត។ យប់

នេះ ព្រះយេស៊ូដែលជាគ្រូពេទ្យម្នាក់យ៉ាងពិសេស ទ្រង់យាងមកស្ថិតនៅអស់កល្បជានិច្ចជាមួយយើង ដើម្បីអញ្ជើញយើងឲ្យបង្កើតមន្ទីរពេទ្យ ជាច្រើនទៀតក្នុងពិភពលោកទាំងមូល និងជាពិសេសនៅក្នុងប្រទេសកម្ពុជាយើងគឺឲ្យយើងបង្កើតមន្ទីរពេទ្យនៃដួងចិត្ត ដែលប្រគល់សេចក្តីស្រឡាញ់ សេចក្តីសង្ឃឹមដល់មនុស្សដែលរកពន្លឺមិនឃើញសោះនៅក្នុងជីវិត។ ព្រះយេស៊ូយាងមកដើម្បីសង្គ្រោះយើង និងព្រះអង្គត្រូវការឲ្យយើងសង្គ្រោះ បងប្អូនឯទៀតៗដែរ ព្រះអង្គឲ្យយើងរំដោះមនុស្សដែលដើរនៅក្នុងភាពងងឹតឲ្យយើងណែនាំមនុស្សដែលវង្វេង ឲ្យគេរកឃើញផ្លូវមួយ ដែលផ្តល់សេចក្តីសង្ឃឹមឲ្យគេវិញ។

យប់នេះ ជាយប់ដែលព្រះយេស៊ូសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញជាពេលដែលព្រះអង្គយាង ចូលនៅក្នុងទុក្ខលំបាករបស់មនុស្សទាំងអស់ ដើម្បីឲ្យទុក្ខលំបាកនេះទៅជាសេចក្តីសង្ឃឹមវិញ។ បើយើង មិនជឿថាទុក្ខលំបាករបស់យើង ការព្រួយបារម្ភរបស់យើង សេចក្តីអស់សង្ឃឹមរបស់យើង ប្រែទៅជាសេចក្តីសង្ឃឹមវិញទេ នោះយើងមិនមែនជាគ្រីស្តបរិស័ទទេ។ យើងជាគ្រីស្តបរិស័ទជឿថា នៅក្នុងភាពងងឹតរបស់មនុស្សនៅក្នុងទុក្ខលំបាករបស់មនុស្ស នោះព្រះយេស៊ូណែនាំឲ្យទៅជាសេចក្តីសង្ឃឹមវិញ។ នៅលើភ្នំបូកគោ យើងមានព្រះវិហារចាស់មួយដែលខ្មែរក្រហមមិនបានវាយចោល។ រួមជាមួយបងប្អូន កាតូលិកក្នុងមណ្ឌលសកម្មភាពខេត្តកំពត យើងបានទៅធ្វើបុណ្យព្រះយេស៊ូសោយទិវង្គតនៅទីនោះ។ យើងបានហែរឈើឆ្កាង និងបានថ្វាយអភិបូជាក្នុងព្រះវិហារ ពេលនោះយើងក៏បាននឹកឃើញដល់របៀបដែលព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង ដោយមានព្រះបន្ទូលថា៖ "ខ្ញុំស្រេកទឹក!"។ ពីលើភ្នំបូកគោមក ខ្ញុំក៏បាននឹកឃើញដល់បងប្អូនទាំងអស់ ជាពិសេសនឹកដល់បងប្អូនដែលគ្មានផ្លូវនៅក្នុងជីវិតនឹកដល់បងប្អូនដែល គ្មានទីពឹងដូចជាស្ត្រីមេម៉ាយ កុមារកំព្រា អ្នកដែលគ្មានការងារធ្វើ អ្នកដែលគ្មានលុយគ្រប់គ្រាន់ដើម្បីរៀនសូត្រ ឬដើម្បីទៅមន្ទីរពេទ្យ។ ខ្ញុំនឹកឃើញអស់អ្នកដែលគ្មានឯកសារត្រឹមត្រូវដើម្បីរស់នៅស្របច្បាប់ នៅក្នុងប្រទេសកម្ពុជា ខ្ញុំនឹកដល់អស់អ្នកដែលគ្មានអំណរសប្បាយនៅក្នុងជីវិតដែរ...។

បងប្អូនជាទីស្រឡាញ់!ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំស្រេកទឹកសម្រាប់មនុស្សលោក " គឺព្រះអង្គមិន ស្រេកសម្រាប់តែមនុស្សដែលលំបាកទេ ប៉ុន្តែព្រះអង្គក៏ស្រេកសម្រាប់មនុស្សដែល គ្មានសីលធម៌នៅក្នុងខ្លួនសម្រាប់មនុស្ស ដែលគ្មានចិត្តមេត្តា

ដែរមានន័យថា ព្រះយេស៊ូយាងមកសម្រាប់មនុស្សទាំងអស់។ ព្រះយេស៊ូមានព្រះបន្ទូលថា៖"ខ្ញុំស្រេកទឹក"ប៉ុន្តែក្រោយមក ព្រះអង្គមានព្រះបន្ទូលថា៖"ឥឡូវនេះ អ្វីៗទាំងអស់បានបង្ហើយហើយ" គឺអ្វីៗទាំងអស់បានបង្ហើយ នៅពេលព្រះអង្គសោយទិវង្គត និងបីថ្ងៃក្រោយ មកព្រះអង្គមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ "ខ្ញុំជាព្រះគ្រីស្តដែលមានព្រះជន្ម គង់នៅខ្ញុំបន្តស្រេកទឹក ដើម្បីឲ្យមនុស្សដែលគ្មាន ទីពឹង និងសេចក្តីសង្ឃឹមមនុស្សដែលខ្វះទឹកនៃអំណរសប្បាយរកឃើញទឹកអស់កល្បជានិច្ចវិញ"។

នៅពេលនេះ ព្រះយេស៊ូត្រូវការឲ្យយើងចេះបើកភ្នែកមើលថា៖" តើនរណាជាបងប្អូនរបស់ខ្ញុំ?" នេះជាសំណួរសម្រាប់យើង នៅក្នុងឆ្នាំនៃធម៌មេត្តាករុណានេះ។ សូមកុំភ្លេចថា៖ "បងប្អូនរបស់ខ្ញុំ គឺអ្នកទាំងអស់ផ្សេងពីខ្ញុំ "។ ហេតុនេះហើយ យើងមានបងប្អូនច្រើនណាស់ ដែលទន្ទឹងរង់ចាំសញ្ញាសម្គាល់នៃភាតរភាព សញ្ញាសម្គាល់នៃចិត្តបម្រើសញ្ញាសម្គាល់នៃធម៌មេត្តាករុណាពីយើង។ ហេតុនេះហើយ បានជាថ្ងៃនេះយើងមកជួបជុំគ្នាច្រៀង អាលេលូយ៉ា ! អាលេលូយ៉ា ! ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ហេតុនេះហើយ ពេញមួយឆ្នាំខាងមុខនេះ ណែនាំឲ្យយើងទៅមុខ ដើម្បីឲ្យយើងចែករំលែកធម៌មេត្តាករុណា ដើម្បីឲ្យយើងមានចិត្តថ្នាក់ថ្នមបងប្អូន ដូចព្រះយេស៊ូមានព្រះហឫទ័យថ្នាក់ថ្នម ដើម្បីឲ្យយើងចាប់អារម្មណ៍ចំពោះបងប្អូនឯទៀតៗ ដូចព្រះយេស៊ូយកព្រះហឫទ័យទុកដាក់ដល់បងប្អូនឯទៀតៗដូច្នេះដែរ។

យប់នេះជាការអស្ចារ្យណាស់ ដោយសារយើងបានទទួលព្រះយេស៊ូដែលជាព្រះបរមគ្រូនៃយើងទទួលព្រះអង្គ ដែលជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ ទទួលព្រះអង្គដែលជាគង្វាល និងដែលជាមិត្តសម្លាញ់របស់យើង ដើម្បីយើងទទួលការសង្គ្រោះពីព្រះអង្គ ដើម្បីយើងចូលយ៉ាងជ្រៅយ៉ាងសកម្ម នៅក្នុងព្រះកាយព្រះអង្គ គឺក្នុងព្រះសហគមន៍ដែល មានព្រះយេស៊ូជាព្រះសិរសាររបស់យើង។ ខ្ញុំមានបទពិសោធន៍មួយយ៉ាងពិសេស គឺនៅពេលខ្ញុំណែនាំសំណាក់ធម៌ ខ្ញុំបានសួរទៅបងប្អូនថា៖" ពេលបងប្អូនទទួលពិធីជ្រមុជទឹកហើយ តើបងប្អូនទទួលបានអ្វី?" មានម្នាក់បានឆ្លើយថា៖ "ខ្ញុំទទួលបានគ្រួសារថ្មីគឺបងប្អូនដែលនៅ ទីនេះជាគ្រួសារថ្មីរបស់ខ្ញុំ"។ ដូចគាត់បាន ឆ្លើយមែន យើងទាំងអស់គ្នាជាគ្រួសារថ្មីរបស់បេក្ខជនទាំង១០៦ នាក់ ដែលទទួលអគ្គសញ្ញាជ្រមុជទឹកនៅក្នុងភូមិភាគរបស់យើង។ យើងជាគ្រួសារថ្មី ដោយមានព្រះយេស៊ូជាព្រះបរមគ្រូជា

គង្វាលដ៏សប្បុរស និងជាមិត្តសម្លាញ់របស់យើង ដែលចាប់ដៃយើងឲ្យធ្វើដំណើរជាមួយគ្នានៅក្នុងព្រះសហគមន៍ និងនៅក្នុងពិភពលោកទាំងមូលដែរ។ សព្វថ្ងៃព្រះសហគមន៍ របស់យើងទន្ទឹងរង់ចាំគ្រីស្តបរិស័ទដែលឈរឡើង ដើម្បីបង្ហាញថាព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ពិភពលោកទាំងមូល ពិសេសសង្គមរបស់យើងនៅប្រទេសកម្ពុជា ក៏ទន្ទឹងរង់ចាំគ្រីស្តបរិស័ទ ដែលជាពន្លឺដែលមានអំណរសប្បាយ បង្ហាញមេត្តាករុណា ដែលខ្លួនបានទទួលពីព្រះជាម្ចាស់ ជួយមនុស្សទាំង អស់ឲ្យមានជីវិតថ្មី គឺជាជីវិតអស់កល្បជានិច្ច។ យប់នេះយើងទាំអស់គ្នា ចូលយ៉ាងជ្រៅក្នុងទំនាក់ទំនង ថ្មីជាមួយព្រះយេស៊ូ ដែលយាងមក ដោយមានព្រះបន្ទូល "ជម្រាបសួរ " ដល់យើងគ្រប់គ្នា។ ពេញមួយឆ្នាំខាងមុខសូមឲ្យយើងបើកត្រចៀកឲ្យធំៗ ដើម្បីស្តាប់ព្រះយេស៊ូ ដែលមានព្រះបន្ទូលខ្សឹបៗ ក្នុងសម្លេង នៃអ្នកតូចតាចមកយើងថា "សូមជម្រាបសួរ"។

ពិតមែនហើយ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ!

អាលេលូយ៉ា! អាលេលូយ៉ា!។ អាម៉ែន។















# ពិធីតែងតាំង
# សម្តេចប៉ាប យ៉ូហានទី២៣ និងសម្តេចប៉ាប យ៉ូហានប៉ូលទី២
# ជាសន្តបុគ្គល

## បងប្អូនជាទីស្រលាញ់

ថ្ងៃនេះរួមជាមួយព្រះសហគមន៍ទាំងមូល យើងមានអំណរសប្បាយសូមស្វាគមន៍សន្តៈពីរនាក់ថ្មី គឺសន្តៈយ៉ូហានទី ២៣ និងសន្តៈយ៉ូហានប៉ូលទី ២។ យើងដឹងថា នៅថ្ងៃនេះទីក្រុងរ៉ូមមានលោកអភិបាល ១០០០ នាក់ ស្មើនឹង ២៥% នៃលោក អភិបាលទាំងអស់។ មានបូជាចារ្យ ៦០០០ នាក់ មានគ្រីស្តបរិស័ទ ១៥០ ម៉ឺននាក់ មាននាយករដ្ឋមន្រ្តី ២៤ នាក់ មានតំណាង ៩៣ ប្រទេសដែលចូលរួម និងមានរៀបចំការផ្សាយផ្ទាល់តាមអ៊ីនធើណែត តាមទូរទស្សន៍ និងមាន ២០០០ លាននាក់ដែលនឹងមើលទូរទស្សន៍ នៅថ្ងៃនេះ ហើយក៏មានអ្នកដែលកំពង់រង់ចាំមើលនៅមុខវិសាលវិហារសន្តៈសិលា ដូចយើងនឹងមើលនៅម៉ោង ៣ រសៀលនេះដែរ។

មានមនុស្ស ២០០០ លាននាក់មើលតាមទូរទស្សន៍ នេះមានន័យថា មានមនុស្សជាច្រើន ដែលមិនមែនជាគ្រីស្តបរិស័ទ បានចាប់អារម្មណ៍នឹងកម្មវិធីនេះ។ មូលហេតុអ្វីមានមនុស្សច្រើនដូចនេះ អង្គុយមើលអធិដ្ឋាននៅក្នុងពិធីមួយបែបនេះ? តើសម្តេចប៉ាបយ៉ូហានទី ២៣ និងសម្តេចប៉ាបយ៉ូហានប៉ូលទី២ បានផ្តល់អ្វីខ្លះ ដល់ពិភពលោកទាំងមូល?

ទីមួយ យើងត្រូវដឹងថាតើសន្តបុគ្គលជានរណា? សន្តៈបុគ្គល ជាមិត្តសម្លាញ់យ៉ាងជិតស្និទ្ធរបស់ព្រះជាម្ចាស់ ដែលកំពុងសម្លឹងមើល និងដែលបានផ្ញើជីវិតទាំងស្រុងទៅព្រះអង្គ។ យ៉ូហានប៉ូលទី ២ និងយ៉ូ ហានទី២៣ បានផ្ញើជីវិតរបស់លោកទាំងស្រុងទៅលើព្រះជាម្ចាស់ ថ្ងៃនេះលោកទាំងពីរកំពុងសម្លឹងមើលព្រះជាម្ចាស់ និងទៅជាមិត្តសម្លាញ់ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ ព្រះសហគមន៍ទទួលស្គាល់ថា លោកទាំងពីរជាសន្តបុគ្គល មានន័យថាលោកជាគំរូសម្រាប់ពិភពលោកទាំងមូល។ សម្តេចយ៉ូហានប៉ូលទី ២ និងសម្តេចយ៉ូហានទី ២៣ បានផ្តល់អត្ថន័យយ៉ាងជ្រៅដល់មនុស្សទាំងអស់។ ក្នុងចំណោមបង ប្អូនដែលអង្គុយនៅទីនេះ ប្រហែលមានបងប្អូនខ្លះស្គាល់ សម្តេច

យ៉ូហាន ទី២៣ ដ្បិតលោកទទួលមរណភាពនៅឆ្នាំ ១៩៦៣ ប៉ុណ្ណោះ។

សម្តេចយ៉ូហានប៉ូលទី ២ មានមនុស្សជាច្រើនស្គាល់លោក។ នៅប្រទេសកម្ពុជាយើងសព្វថ្ងៃ ទោះបីមិនមែនជាគ្រីស្តបរិស័ទក៏គេស្គាល់លោកដែរ។ សម្តេចទេពវង្សក៏ស្គាល់លោកដែរ។ ក្នុងរយៈពេល ២៦ឆ្នាំជាសម្តេចប៉ាប គឺពីឆ្នាំ ១៩៧៨ រហូតដល់ឆ្នាំ២០០៥ លោកបានធ្វើដំណើរជុំវិញពិភពលោក ទៅសួរសុខទុក្ខគេជាង ១០០ ប្រទេស។ ប្រទេសកុម្មុយនីសស្អប់សាសនាក៏លោកបានទៅដល់ដែរ។ ព្រឹត្តិការណ៍នេះ បានធ្វើឲ្យពិភពលោកទាំងមូលទទួលកម្លាំងថ្មី នេះជាមូលហេតុ ដែលថ្ងៃនេះ ក្នុងពិភពលោកទាំង មូលមានមនុស្សជាង ២០០០ លាននាក់ បានចាប់អារម្មណ៍នឹងកម្មវិធីនេះ។ ។

សម្តេចយ៉ូហានទី ២៣ ឡើងជាសម្តេចប៉ាប ក្នុងវ័យ ៧៨ឆ្នាំ។ លោកជាមនុស្សដ៏សប្បុរសដែល មានចិត្តល្អ លោកទៅសួរសុខទុក្ខកូនក្មេង អ្នកក្រីក្រ អ្នកជំងឺ។ល។ ពេលនោះប្រជាជនភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយសារសម្តេចប៉ាបពីមុនមិនដែលចេញក្រៅសោះ ប៉ុន្តែសម្តេចយ៉ូហានទី២៣ បានចេញ ពីទីក្រុងរ៉ូមទៅជួបក្មេងៗនៅតាមផ្លូវ ទៅជួបអ្នកជាប់ពន្ធនាគារ ទៅសួរសុខទុក្ខគ្រីស្តបរិស័ទតាមព្រះវិហារនានា...។ ប្រជាជនភ្ញាក់ផ្អើល ព្រោះយល់ឃើញថាសម្តេចប៉ាបមិនមែនជាព្រះជាម្ចាស់ដែលមនុស្សលោកទាក់ទងមិនបាន ប៉ុន្តែលោកសុខចិត្តចុះពីបល្ល័ង្កមកដើម្បីសួរសុខទុក្ខប្រជាជន និងធ្វើដំណើរជាមួយគេ។ ជាងនេះទៅទៀត សម្តេចប៉ាបបានណែនាំព្រះសហគមន៍ឲ្យកើតសាជាថ្មី ដោយបានរៀបចំមហាសន្និបាតវ៉ាទីកង់ទី ២ ដែលជាកិច្ចប្រជុំរបស់លោកអភិបាលទូទាំងពិភពលោកទាំងមូល។

សម័យនោះមានលោកអភិបាល ២៥០០ នាក់ ដែលបានទៅជួបជុំជាមួយសម្តេចប៉ាប រយៈពេលបីបួនឆ្នាំ ដើម្បីរិះគិតអំពីព្រះសហគមន៍យើង។ ក្នុងនោះមានលោកអភិបាលអ៊ីវ៉ាម៉ូសដែរ ដែលបានចូលរួម ដើម្បីរិះគិតថា តើព្រះសហគមន៍របស់យើងត្រូវធ្វើដូចម្តេច ដើម្បីធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោកបច្ចុប្បន្ននេះ?។ សម្តេចប៉ាបណែនាំឲ្យមានខ្យល់ថ្មីចូលនៅក្នុងព្រះសហគមន៍ ឲ្យព្រះសហគមន៍ផ្តល់សក្ខីភាពថ្មីចំពោះពិភពលោកទាំងមូល ដោយយល់ថា ការពិបាកចិត្ត ការសប្បាយ ការអស់សង្ឃឹមរបស់មនុស្សលោក ជាការពិបាកចិត្ត ការសប្បាយ ការអស់

សង្ឃឹមរបស់ព្រះសហគមន៍ដែរ។ នេះណែនាំឲ្យគ្រីស្តបរិស័ទទូទាំងពិភពលោកចាប់ផ្តើមយល់ចិត្តគ្នាច្បាស់ទៅៗ។

សម្តេចប៉ាបយ៉ូហានទី ២៣ បានណែនាំឲ្យមនុស្សមានសេចក្តីសង្ឃឹមថ្មី ជាពិសេសនៅថ្ងៃបើកមហាសន្និបាត ដែលមានលោកអភិបាល ២៥០០ នាក់ ជាអ្នកបានចូលរួមប្រជុំនោះហែជាជួរចម្ងាយ ៣០០០ម៉ែត្រ ចូលទៅក្នុងព្រះវិហារសន្តៈសិលា។សម្តេចប៉ាបមានប្រសាសន៍នៅមុខប្រជាជនដោយ អស់ពីចិត្តរបស់លោកថា៖ "យប់នេះ ផ្ទៃមេឃនិងផែនដីជួបជុំគ្នា ជំនឿ សេចក្តីសង្ឃឹម ធម៌មេត្តាករុណា សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោកដែលព្រះអង្គបានបង្កើតមក ណែនាំយើងយប់នេះ ឲ្យរួមជាមួយគ្នាទទួលនូវសេចក្តីសុខពីព្រះអង្គ និងឲ្យមនុស្សទាំងអស់ ត្រូវធ្វើអំពើល្អដើម្បីឲ្យមនុស្សលោកទៅជាមនុស្សលោកថ្មី " ។ ពេលសម្តេចប៉ាបមានប្រសាសន៍ដូចនេះ ណែនាំឲ្យពិភពលោកទាំងមូលសប្បាយ ចិត្តយ៉ាងខ្លាំង។ សម្តេចប៉ាបមានប្រសាសន៍ ទៀតថា៖ " ពេលទៅផ្ទះវិញ សូមបងប្អូនថើបកូនរបស់ខ្លួន ដោយផ្ទាល់ហើយប្រាប់ថា នេះជាស្នាមថើបរបស់សម្តេចប៉ាប។ ប្រសិនបើបងប្អូនជួបទុក្ខលំបាក ហើយស្រក់ទឹកភ្នែកចូរនឹកឃើញថា ទាំងទុក្ខលំបាកទាំងអំណរសប្បាយរបស់បងប្អូន គឺជាទុក្ខលំបាកនិងក៏ជាអំណរសប្បាយ របស់សម្តេចប៉ាបដែរ"។ សម្តេចប៉ាបបាន បង្ហាញថា ព្រះសហគមន៍ជាក្លិបមួយរបស់មនុស្ស និងលោកអញ្ជើញមនុស្សក្នុងពិភពលោកទាំងមូល ឲ្យទៅជាក្រុមគ្រួសារតែមួយ ដើម្បីកសាងសន្តិភាពនិង ភាតរភាព។

សព្វថ្ងៃនេះ មានមនុស្សដែលស្គាល់សម្តេចយ៉ូហានទី ២៣ បានផ្តល់សក្ខីភាពថា៖ "សម្តេចយ៉ូ ហានទី២៣បានផ្តល់ កម្លាំងថ្មី សេចក្តីសង្ឃឹមថ្មី ឲ្យយើងយល់ថាពិភពលោករបស់យើងមិនអស់សង្ឃឹមទេ គឺមនុស្សដែលមានឆន្ទៈដ៏ល្អប្រសើរ អាចបង្កើតសេចក្តីសុខសាន្តបាន ទោះបីពិភពលោករបស់យើងនៅ មានសង្គ្រាមមានការរើសអើងខ្លះក៏ដោយ "។ ក្នុងសារលិខិតចុងក្រោយមួយមុនលោកទទួលមរណភាពមានចំណងជើងថា៖ " សេចក្តីសុខសាន្តលើផែនដី " គឺជាសារលិខិតទីមួយ ដែលលោកអញ្ជើញមនុស្ស ទាំងអស់នៅក្នុងពិភពលោកទាំងមូល មិនមែនតែគ្រីស្តបរិស័ទគឺមនុស្សដែលមានឆន្ទៈដ៏ល្អ មានចិត្ត សប្បុរស មានចិត្តគំនិតចង់កសាងពិភពលោកថ្មីឲ្យកសាងសន្តិភាពរួមគ្នា ដោយសារមនុស្សយើងមាន ព្រះជាម្ចាស់តែមួយជាព្រះបិតា

មានព្រះជាម្ចាស់តែមួយដែលបានបង្កើតយើងទាំងអស់គ្នា ដូច្នេះយើងទាំងអស់គ្នាជាក្រុមគ្រួសារតែមួយ និងជាបងប្អូនបង្កើតនឹងគ្នា។ សេចក្ដីនេះណែនាំឲ្យមនុស្សមានសេចក្ដីសង្ឃឹមយ៉ាងពិតប្រាកដ និងជាមូលហេតុដែលថ្ងៃនេះ មានបងប្អូនជាច្រើនមកអង្គុយស្ដាប់អង្គុយមើល អង្គុយអធិដ្ឋានជាមួយសន្ដៈយ៉ូហានទី ២៣ ព្រោះនឹកឃើញដល់លោកដែលបានផ្ដល់កម្លាំងថ្មីឲ្យពិភពលោកយើងនៅសម័យដែលពិភពលោកទើបតែចេញពីភាពងងឹតនៃសង្គ្រាមលោកលើកទីពីរ។

សម្ដេចយ៉ូហានប៉ូលទី២ ទទួលមុខងារជាសម្ដេចប៉ាបនៅអាយុ ៥៨ឆ្នាំ។ លោកអញ្ជើញមកពីប៉ូឡូញ ជាប្រទេសកុម្មុយនីស្ដដ៏តឹងតែង ដែលបិទសិទ្ធិសេរីភាពប្រជាជន។ លោករស់នៅក្នុងបរិយាកាស ដ៏លំបាក ដូចយើងរស់នៅក្នុងសម័យប៉ុលពត។ លោកចូលទេវវិទ្យាល័យនៅកន្លែងស្ងាត់ កុំឲ្យរដ្ឋាភិបាលកុម្មុយនីស្ដដឹង ដោយសារគេមិនអនុញ្ញាតឲ្យព្រះសហគមន៍មានសកម្មភាពណាមួយទេ។ លោកត្រូវបានជ្រើសរើសជាសម្ដេចប៉ាប នៅខែតុលាឆ្នាំ១៩៧៨។ ពេលនោះពិភពលោកទាំងមូលភ្ញាក់ផ្អើល យ៉ាងខ្លាំងដោយសារមានសម្ដេចប៉ាបមកពីប្រទេសប៉ូឡូញ។ នេះជាលើកទីមួយហើយដែលតាំងពីរាប់រយឆ្នាំមុន គេរើសសម្ដេចប៉ាប ដែលមិនមែនជាជនជាតិអ៊ីតាលី។

ក្នុងអភិបូជាតែងតាំងជាសម្ដេចប៉ាប ពេលនោះលោកបានមានប្រសាសន៍ដូចព្រះយេស៊ូមានព្រះបន្ទូល "កុំខ្លាចអី!" "សូមបើកទ្វារថ្វាយព្រះយេស៊ូ សូមបើកទ្វារថ្វាយព្រះយេស៊ូយាងចូលទៅគ្រប់ទីកន្លែង គ្រប់ទីតាំងសូមបើកទ្វារព្រំដែននៃប្រទេសនីមួយៗ សូមបើក ទ្វារសេដ្ឋកិច្ច សូមបើកទ្វារនយោបាយ សូមបើកទ្វារវប្បធម៌ សូមបើកទ្វារឲ្យប្រជាជនទាំងមូលទាក់ទងគ្នា សូមបើកទ្វារឲ្យមានការអភិវឌ្ឍន៍។ ចូរកុំខ្លាចអី! ដ្បិតព្រះយេស៊ូគ្រីស្ដ ជាអម្ចាស់ឈ្វេងយល់ច្បាស់អំពីដួងចិត្តរបស់មនុស្សយើង ព្រះអង្គដឹងច្បាស់ ថាមានអ្វី នៅក្នុងជម្រៅនៃដួងចិត្តរបស់យើង"។ សុន្ទរកថានេះ មានន័យជ្រាលជ្រៅណាស់ ចំពោះប្រទេសកុម្មុយនីស្ដ ដែលគេបិទសិទ្ធិសេរីភាពខាងសាសនា និងសិទ្ធសេរីលើអ្វីៗទាំងអស់។ សារនេះជាខ្យល់ថ្មីដែលចូលនៅ ក្នុងព្រះសហគមន៍ដែរ។

នៅឆ្នាំ ១៩៧៩ សម្ដេចប៉ាបបានទៅប្រទេសប៉ូឡូញជាស្រុកកំណើតរបស់លោក ស្ថិតនៅចំពោះមុខ មនុស្សជាង ១ លាន ៥សែននាក់ លោកមិនខ្លាចអ្វីសោះ លោកមានប្រសាសន៍យ៉ាងក្លាហានថា៖"អត់មានរដ្ឋាភិបាលណាមួយដែលអាចបិទទ្វាររបស់

ព្រះយេស៊ូបាន!"។ ពេលនោះប្រជាជនសប្បាយចិត្តណាស់ គេទះដៃយ៉ាងយូរ ដោយសារនេះជាលើកទីមួយហើយ ដែលគេបានស្តាប់ឮពាក្យដូចនេះ ព្រោះប្រជាជននៅទីនោះត្រូវបានពួកកុម្មុយនីស្តបិទសិទ្ធិសេរីភាពជាយូរឆ្នាំមកហើយ។ លោកមានប្រសាសន៍បន្តទៀតថា៖ "អត់មាននយោបាយណា អត់មានប្រទេសមួយណា ឥតមានរដ្ឋអំណាចមួយណា ដែលអាចបិទទ្វារ របស់ព្រះយេស៊ូបាន ដោយសារព្រះយេស៊ូឈ្នះសេចក្តីស្លាប់ និងឈ្នះលើភាពងងឹតដែលមាននៅក្នុងដួងចិត្តរបស់មនុស្ស "។ ដោយសារសុន្ទរកថានេះ បន្តិចក្រោយមកលទ្ធិកុម្មុយនីស្តក៏បានដួលរលំ ធ្វើឲ្យប្រជាជនរស់នៅក្នុងសេចក្តីសុខសាន្តសាជាថ្មីជាមួយនឹងប្រសាសន៍សម្តេចប៉ាបថា៖ "កុំខ្លាចអី!"។

សម្តេចប៉ាបយ៉ូហានប៉ូលទី ២ បានធ្វើដំណើរជុំវិញពិភពលោកទាំងមូល ប្រមូលមនុស្សឲ្យជួបជុំគ្នា ឲ្យ គេមានសេចក្តីសុខមានសេចក្តីសង្ឃឹមសាជាថ្មី។ សម្តេចប៉ាបទៅមីគីជាប្រទេសដែលបិទសិទ្ធិខាង សាសនាលោកទៅប្រកាសថា៖ " មានតែព្រះយេស៊ូគ្រីស្តទេ ដែលណែនាំឲ្យជីវិតរបស់មនុស្សយើងមានតម្លៃថ្លៃថ្នូរ។ មានតែព្រះយេស៊ូគ្រីស្តទេដែលណែនាំឲ្យយើងមានសេរីភាពនៅក្នុងខ្លួនបាន"។ពេលលោកអញ្ជើញទៅភីលីពីនមានប្រជាជន ៥លាននាក់ជួបជុំគ្នាដើម្បីស្តាប់លោកមានប្រសាសន៍។ នៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោកទាំងមូលមិនដែលមានអង្គប្រជុំណាប្រមូលមនុស្សយ៉ាងច្រើនដូចនេះទេ ប៉ុន្តែសម្តេចប៉ាបយ៉ូហាន ប៉ូលទី ២ អាចធ្វើបាន។

នៅឆ្នាំ ១៩៨៤ លោកបានចាប់ផ្តើមរៀបចំទិវាយុវជនពិភពលោក ដែលមានអ្នកខ្លះគិតថាលោកមិនអាចធ្វើបាន។ពីរឆ្នាំបន្ទាប់មកមានទិវាយុវជនពិភពលោកនៅប៉ូឡូញ។ សម្តេចប៉ាបយ៉ូហានប៉ូលទី២ ចាប់ផ្តើមទិវាយុវជននេះ ជាមួយនឹងយុវជន យុវនារីដ៏ច្រើនកុះករ។ លោកប្រកាសនៅចំពោះមុខគេនូវសេចក្តីពិត ក្នុងនាមព្រះយេស៊ូថា៖ " សូមការពារថែរក្សាជីវិតព្រោះជីវិតរបស់យើងមានតម្លៃណាស់ យើងទទួលជីវិតពីថ្ងៃកំណើតរហូតដល់ថ្ងៃស្លាប់ " ពេលនោះយុវជនជាច្រើនគេយល់យ៉ាងច្បាស់ ហើយគេទទួលនូវសេចក្តី ដែលលោកប្រកាស។

នៅឆ្នាំ ១៩៨៨ ពេលនោះខ្ញុំមានអាយុ ១៨ ឆ្នាំ។ កាលនោះសម្តេចប៉ាបបានអញ្ជើញទៅទីក្រុងរបស់ខ្ញុំ។ មានយុវជនយុវនារី ៥ ម៉ឺននាក់មកជួបជុំគ្នា ពេលនោះលោកបានប្រកាសយ៉ាងខ្លាំងៗអំពីសេចក្តីស្រឡាញ់។ លោកមានប្រសាសន៍ថា៖

"នៅក្នុងជីវិតរបស់យើង គឺយើងរស់តែម្តង។ នៅក្នុងជីវិតរបស់យើង គឺយើងស្លាប់តែម្តង ហើយយើងស្រឡាញ់តែម្តងដែរ "ពេលនោះយុវជនទះដៃខ្លាំងណាស់ ដោយសារគេទទួលសេចក្តីពិតពីសម្តេចប៉ាប ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត។ ទិវានេះនៅតែបន្តណែនាំឲ្យយុវជនទាំងអស់ទទួលកម្លាំងថ្មីរហូតដល់សព្វថ្ងៃ។ នេះជាឥទ្ធិពលរបស់សម្តេចប៉ាប យ៉ូហានប៉ូលទី ២ ហើយនេះក៏ជាហេតុដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ តែងតាំងលោកជាឧបការីនៃ ទិវាយុវជនពិភពលោកកាលពីប៉ុន្មានអាទិត្យមុននេះ។

សម្តេចប៉ាបយ៉ូហានប៉ូលទី ២ បានណែនាំឲ្យពិភពលោករបស់យើង ចាប់ផ្តើមចូលនៅ ក្នុងការសន្ទនាគ្នាទៅវិញទៅមក។ ជាពិសេសនៅឆ្នាំ១៩៨៦ លោកបានអញ្ជើញអ្នកដឹកនាំសាសនានានាទូទាំងពិភពលោក មកជួបជុំគ្នានៅទីក្រុងអាស៊ីស៊ីជាទីក្រុងរបស់សន្តៈ ហ្វ្រង់ស្វ័រ ដើម្បីអធិដ្ឋានសម្រាប់សន្តិភាពនៅក្នុងពិភពលោក។ នៅពេលនោះសម្តេចព្រះសង្ឃរាជ ទេពវង្ស បាននិមន្តចូលរួមក្នុងនាមពុទ្ធសាសនិកនៅប្រទេសកម្ពុជា។ ក្នុងឱកាសនោះ ថ្នាក់ដឹកនាំនៃសាសនា ទាំងអស់បានមើលមុខគ្នាទៅវិញទៅមក ដោយដឹងថាយើងអាចអង្គុយជិតគ្នា ដើម្បីអធិដ្ឋានសម្រាប់សេចក្តីសុខសន្តិភាពរបស់ពិភពលោកទាំងមូល។ សម្តេចយ៉ូហានប៉ូលទី២ មានសេចក្តីក្លាហានធ្វើកិច្ចការទាំងនេះ ដោយសារលោកមានជំនឿ ដែលណែនាំឲ្យឈ្នះឧបសគ្គទាំងអស់ដែលណែនាំឲ្យសេចក្តីសង្ឃឹមក្លាយទៅជាគោលការណ៍យ៉ាងពិតប្រាកដ។ សេចក្តីសង្ឃឹមសេចក្តីស្រឡាញ់ និងជំនឿណែនាំឲ្យអ្វីៗទាំងអស់អាចរីកចម្រើនបាន។ សម្តេចយ៉ូហានប៉ូលទី ២ ជាគំរូមួយឲ្យយើងឃើញយ៉ាងច្បាស់ថា ពិតមែនជំនឿរបស់យើងណែនាំឲ្យយើងអាចលើកភ្នំ ពីកន្លែងមួយទៅដាក់កន្លែងមួយ ទៀតបាន។

សម្តេចប៉ាបទទួលមរណភាពនៅឆ្នាំ ២០០៥។ កាលពីឆ្នាំ ១៩៨១ មានគេលបបាញ់លោក និងតាំងពីពេលនោះមក កម្លាំងកាយរបស់លោកបានចុះខ្សោយទៅៗ។ នៅឆ្នាំ២០០៤ លោកបានអញ្ជើញទៅ ប្រទេសបារាំងដើម្បីពិនិត្យជំងឺ និងទៅលួរដ៍ដើម្បីទូលអង្វរព្រះនាងម៉ារី។ នេះបង្ហាញថា សម្តេចប៉ាបបានការពារជីវិតតាំងពីថ្ងៃ កំណើតរហូតដល់ថ្ងៃចុងក្រោយ ដែលលោកចាស់ជរា លោកអស់កម្លាំង គឺលោកបង្ហាញថាជីវិតយើងមានតម្លៃណាស់ ដូចលោកបានមានប្រសាសន៍។ ។

នៅរ៉ូម មួយអាទិត្យមុនទទួលមរណភាព ជាថ្ងៃបុណ្យចម្លង សម្តេចប៉ាបបានបង្ហាញ

ខ្លួនតាមបង្អួច នៅវិសាលវិហារសន្តៈសិលា លោកលែងនិយាយបាន លោកគាន់តែលើក ដៃដើម្បីប្រទានពរដល់ពិភពលោកទាំងមូល នេះជាសញ្ញាចុងក្រោយ ដើម្បីបង្ហាញថាលោកស្រឡាញ់យើង។ ពេលនោះយុវជននិងប្រជាជនជាច្រើន ដែលនៅទីនោះ គេអធិដ្ឋានអង្វរព្រះជាម្ចាស់សូមប្រោសប្រណីដល់លោក និងថ្ងៃចុងក្រោយគេអាន អត្ថបទគម្ពីរជូនលោកស្តាប់ រហូតដល់លោកទទួលមរណភាពនិងចូលរួមជាមួយព្រះជាម្ចាស់ ក្នុងព្រះរាជ្យរបស់ព្រះអង្គ។

សម្តេចយ៉ូហានទី ២៣ និងសម្តេចយ៉ូហានប៉ូលទី ២ ត្រូវបានតែងតាំងជាសន្តបុគ្គល ដោយផ្អែកលើគុណសម្បត្តិរបស់លោកទាំងពីរ ដែលបានណែនាំឲ្យមនុស្សយើងមានសេចក្តីសង្ឃឹម។ ជីវិតរបស់លោកទាំងពីរ បង្ហាញឲ្យយើងឃើញថា លោកមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ ដោយសារការអធិដ្ឋាន។ លោកទាំងពីរបានអធិដ្ឋានច្រើនណាស់សម្រាប់ពិភពលោកយើង។ សម្តេចយ៉ូហានប៉ូលទី ២ នៅចំពោះមុខមនុស្ស ៥ លាននាក់ ក៏លោកនៅតែអធិដ្ឋានដែរ នេះជាការដ៏អស្ចារ្យណាស់។

ដូច្នេះយើងសូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានមកយើងនូវសន្តបុគ្គលថ្មីពីរនាក់ទៀត។ យើង សូមអង្វរសន្តៈយ៉ូហានទី ២៣ និងសន្តៈយ៉ូហានប៉ូលទី២ សូមលោកបើកភ្នែកនៃដួងចិត្តរបស់យើង ឲ្យយើងចេះអធិដ្ឋាន ឲ្យយើងទៅជាមនុស្សដែលបង្កើតសេចក្តីសង្ឃឹមដល់អ្នកដទៃ ដោយសារព្រះយេស៊ូគ្រីស្តជាជីវិត ដោយសារព្រះយេស៊ូគ្រីស្តមានព្រះជន្មថ្មីដ៏រុងរឿង។ អាលេលូយ៉ា! អាម៉ែន។










